# គណបក្សជាតិខ្មែរប្រចាំប្រទេសអូស្ត្រាលី
## KHMER NATION PARTY IN AUSTRALIA

# សារលិខិតសូមព្រះរាជសន្តោសដោះលែងទោស

សូមក្រាបថ្វាយបង្គំទូលព្រះករុណា ព្រះរាជតេជះដ៏កល់លើត្បូង ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន អគ្គមហាបុរសរតន៍ ព្រះចៅក្រុងកម្ពុជាធិបតី ។

ទូលព្រះបង្គំជាកូនចៅរបស់ព្រះអង្គឈ្មោះ ធឿន_រតនា ជាអតីតសមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិច ហើយសព្វថ្ងៃជាអ្នកសំរបសំរួលនិងទំនាក់ទំនងសាខាគណបក្សជាតិខ្មែរគ្រប់រដ្ឋនៅក្នុងប្រទេសអូស្ត្រាលី មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង សូមទូលថ្វាយនិងសុំព្រះរាជយោបល់ស្តីពីការកាត់ទោសដាក់ពន្ធនាគារ ចំពោះលោក ហែន_វិភាគ ជាអតីតចាងហ្វាងសារពត៌មាន «សេរីភាពថ្មី» ពីសំណាក់តុលាការកំពូលនៃរាជរដ្ឋាភិបាលខ្មែរយើងកាលពីថ្ងៃទី ២៣សីហា១៩៩៦ កន្លងមកថ្មីៗនេះ ។

ទូលព្រះបង្គំបានយល់ឃើញថា ប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ហាក់ដូចមិនសូវល្អតលាស់ទៅមុខ ទាល់តែសោះនូវលទ្ធិប្រជាធិបតេយ្យ ក៏ដូចសេរីភាពក្នុងការបញ្ចេញមតិយោបល់ហើយនិងប្រព័ន្ធតុលាការផងដែរ ។ លោក ហែន_វិភាគ ត្រូវពួកអ្នកកាន់អំណាចសព្វថ្ងៃបានចាប់ដាក់ពន្ធនាគារ ដោយហេតុតែលោកបានបញ្ចេញមតិគាំទ្រប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ថា ជាយុទ្ធនាការបង្ក្រាបសេរីភាពរបស់សារពត៌មាន ដែលជាការរំលោភច្បាប់ទាំងស្រុង ផ្ទុយពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស នាឆ្នាំ១៩៩១ទៀតផង ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ,

ទូលព្រះបង្គំធ្លាប់បានដឹងថា ព្រះអង្គទ្រង់ជាមហាក្សត្រមានទសពិធរាជធម៌ ហើយទ្រង់តែងតែរកយុត្តិធម៌ និងអាណិតអាសូរប្រោសប្រណីរំដោះទុក្ខសោករបស់ប្រជារាស្ត្រជានិច្ចនិរន្តរ៍ ទូលបង្គំជាខ្ញុំ សូមព្រះអង្គទ្រង់ព្រះរាជតម្រិះ មេត្តាជួយធ្វើអន្តរាគមន៍ ដោះលែងលោក ហែន_វិភាគ អតីតចាងហ្វាងសារពត៌មាន «សេរីភាពថ្មី» តាមព្រះរាជសន្តោស ។

មុននិងថ្វាយបង្គំលា ទូលបង្គំសូមថ្វាយនូវព្រះពុទ្ធពរ៥ប្រការ សូមឱ្យព្រះអង្គនិងអគ្គមហេសី ព្រមទាំងព្រះញាតិវង្ស ទទួលនូវព្រះពលកាយដ៏ខ្លាំងក្លា ព្រះប្រាជ្ញាវាងវៃ ព្រមទាំងមានព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏ត្រជាក់ដល់ប្រជាពលរដ្ឋខ្មែរជាយូរអង្វែងតទៅ ។

ក្រុងមែលបួន ,ថ្ងៃទី២៤ សីហា ១៩៩៦

[signature]

ទូលបង្គំ ធឿន រតនា

ទីស្នាក់ការ : 14 Carbine Ave , Clayton South
Vic . 3169 . Australia
Tel & Fax : 613 9551 3442

គណបក្សជាតិខ្មែរ
KHMER NATION PARTY
PARTI DE LA NATIÒN KHMÈRE

**P.O. Box 402, Jonestown, PA 17038 Tel./Fax (717) 274-2830**

**សូមក្រាបបង្គំទូលថ្វាយ**

ព្រះករុណាព្រះបាទសម្តេច នរោត្តម-សីហនុវរ្ម័ន និង ព្រះអគ្គមហេសី ព្រះមហាក្សត្រ
នៃ **ព្រះរាជាណាចក្រកម្ពុជា**

សូមព្រះអង្គទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមខ្ញុំព្រះបង្គំផ្ទាល់ និង ជាតំណាងសមាជិក-សមាជិកា នៃគណបក្សជាតិខ្មែរ នៅសហរដ្ឋអាមេរិក ខ្ញុំព្រះបង្គំមានការសោកស្តាយយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចរបស់តុលាការកំពូល ដែលបានកាត់ទោស និងចាប់ខ្លួនលោក ហែន វិភាគ យកទៅដាក់គុកតេកា (T3) កាលពីថ្ងៃទី ២៣ ខែសីហា ១៩៩៦ **កន្លងមកនេះ** ។

ខ្ញុំព្រះបង្គំ សូមក្រាបថ្វាយក្រោមល្អងធូលីព្រះបាទ ថ្វាយចុតហ្មាយនេះចំពោះព្រះអង្គ និងព្រះអគ្គមហេសី ជាម្ចាស់ជីវិតតំកល់លើត្បូង សូមព្រះអង្គព្រះរាជទានទោសជួយរំដោះទុក្ខដល់កូនចៅព្រះអង្គដែលធ្លាប់បានជ្រកកោនក្រោមម្លប់ឆ័ត្រជាក់នៃព្រះបារមីព្រះអង្គ ឱយបានផុតពីការផ្តន្ទាទោសដាក់ក្នុងពន្ធនាគារ និងការពិន័យជាប្រាក់ដល់លោក ហែន វិភាគ និងដោះលែងឱយមានសេរីភាពវិញ តាមព្រះរាជតម្រិះ និងព្រះ**ទ័យអនុគ្រោះរបស់ព្រះអង្គផង** ។

ព្រះករុណាជាអម្ចាស់ ! ពីភពលោក និងប្រជានុរាស្ត្រខ្មែរ ជាអ្នកស្លូតត្រង់តែងតែមានការកោតសរសើរ និង អបអរសាទរពីព្រះតម្រិះរបស់ព្រះអង្គ ក្នុងការដឹកនាំនាំកម្ពុជា ឱយបានជួបតែសេចក្តីសុខ សេចក្តីចំរើន និងភាពរុងរឿងក្នុងរយៈដែលព្រះអង្គនៅគ្រងរាជ្យសម្បត្តិ និងនៅពេលដែលព្រះករុណាកាន់**តំណែងជាព្រះប្រមុខរដ្ឋ** ។ ព្រះករុណាជាអម្ចាស់ ! ពេលនេះព្រលឹងខ្មែរជឿ **រកព្រះអង្គហើយ** ។

សេចក្តីទូលពុំទូរ សូមព្រះករុណា និងព្រះអគ្គមហេសី សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស**ដល់ខ្ញុំព្រះបង្គំ** ជាប្រជានុរាស្ត្ររបស់ព្រះអង្គ ។

**ចម្លងជូន** :
- **សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រី ទី១**
- **ឯ.ឧ. សម្តេច នាយករដ្ឋមន្ត្រី ទី២**

**ធ្វើនៅ[illegible]**. ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៩៦

Léng Bonha

ខ្ញុំព្រះបង្គំ **ឡេង [illegible]**

# លិខិតសុំព្រះរាជទានលើកលែងទោស

សូមក្រាបបង្គំទូលសម្តេចព្រះបាទនរោត្តមសីហនុវរ្ម័ន   ព្រះចៅប្រទេសកម្ពុជា ។

សម្តេច ឪជាម្ចាស់,

ទូលព្រះបង្គំអ៊ិន-សុផានី   តំណាងប្រជាពលរដ្ឋខ្មែរនៅទីក្រុងស្តុកតុន   រដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក ។   សូមបង្អោនកាយអង្វរព្រះទ័យព្រះជាម្ចាស់   មេត្តាព្រះរាជទានលើកលែងទោសដល់លោកហែម-វិភាគ   ចាងហ្វាងកាសែតសេរីភាពថ្មី   ដែលត្រូវបានរាជរដ្ឋាភិបាលបច្ចុប្បន្នចាប់ដាក់គុកក្នុងពេលថ្មីៗនេះ ។

សម្តេច ឪជាម្ចាស់,

មានតែសម្តេច ឪជាម្ចាស់ទេ   ដែលអាចជួយសង្គ្រោះអាយុជីវិតឬយ៉ាងហោចណាស់ជួយបន្ធូរបន្ថយទុក្ខទោសដល់កូនចៅព្រះអង្គ   ដែលកំពុងហែលឆ្លងមហាទុក្ខសោកសព្វថ្ងៃ   ពិសេសពេលនេះទូលព្រះបង្គំជឿថា   ព្រះអង្គមិនបោះបង់ចោលឡើយនូវពាក្យដង្ហោយរបស់កូនចៅសុំព្រះបិតាជាតិជួយ ។

ពាក្យគួរពុំគួរសូមព្រះរាជទានទោស ។

ក្រាបបង្គំទូលនៅទីក្រុងស្តុកតុន   ស.រ.អា.
ថ្ងៃទី២៣   សីហា   ១៩៩៦

ទូលបង្គំ

អ៊ិន-សុផានី

# គណបក្សជាតិខ្មែរប្រចាំប្រទេសអូស្ត្រាលី

## KHMER NATION PARTY IN AUSTRALIA

# សារលិខិតសូមទ្រង់សន្ដោសដោះលែងទោស

សូមថ្វាយបង្គំសម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទីមួយ សូមទ្រង់ជ្រាប ។

ទូលបង្គំឈ្មោះ ធឿន_រតនា ជាអ្នកសំរបសំរួលនិងទំនាក់ទំនងសាខាគណបក្សជាតិខ្មែរគ្រប់រដ្ឋនៅក្នុងប្រទេសអូស្ត្រាលី មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយបានដឹងថា តុលាការកំពូលនៃរាជរដ្ឋាភិបាលយើងបានកាត់ទោសលោក ហែន_វិភាគ ជាអតីតចាងហ្វាងសារពត៌មាន «សេរីភាពថ្មី» ជាប់ពន្ធនាគាររយៈមួយឆ្នាំ និងពិន័យជាប្រាក់៥លានរៀល ដោយចោទប្រកាន់ពីបទផ្សាយពត៌មានមិនពិត ។

សម្ដេចក្រុមព្រះជាទីគោរព ,

ទូលបង្គំមានការសោកស្ដាយជាខ្លាំង ដោយបានឃើញហេតុការណ៍ខាងលើកើតឡើង ។

ទូលបង្គំយល់ឃើញថា ការបញ្ចេញមតិយោបល់របស់លោក ហែន_វិភាគ គឺជាគំនិតដែលគាំទ្រលទ្ធិប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ ជាការធម្មតាចំពោះអ្នកដែលស្រឡាញ់របបប្រជាធិតេយ្យ រមែងតែងតែមានឧត្តមគតិ និងគំនិតផ្ទុយស្រឡះពីអ្នកដែលប្រកាន់យកលទ្ធិកុម្មុយនិស្ត។ តែទោះបីយ៉ាងណាក៏ដោយ ប្រទេសក្នុងសកលលោកណាដែលមានលទ្ធិប្រជាធិបតេយ្យត្រឹមត្រូវ និងច្បាស់លាស់ ប្រទេសនោះនឹងឆ្លងផុតនូវអំណាចផ្ដាច់ការ អំពើហឹង្សា ពុករលួយ ហើយឈានចូលទៅរកវឌ្ឍនភាព ចំរើនល្អលាស់ពុំខាន ។

ទូលបង្គំខ្ញុំយល់ឃើញថា លោកហែន_វិភាគ គ្រាន់តែបញ្ចេញមតិយោបល់ដែលស្របតាមការធានារបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសឆ្នាំ១៩៩១ ។ ដូច្នេះ គាត់មិនត្រូវបានជាប់ពន្ធនាគារឡើយ។

ទូលបង្គំសូមសំណូមពរដល់សម្ដេចក្រុមព្រះ ទ្រង់មេត្តាធ្វើអន្តរាគមន៍យ៉ាងណាដើម្បីឱ្យលោក ហែន_វិភាគ បានរួចខ្លួនពីការចោទប្រកាន់របស់តុលាការ ហើយនឹងបានចេញពីពន្ធនាគារក្នុងពេលនាអនាគតដ៏ខ្លីខាងមុខនេះផង ។

ទូលបង្គំមានសេចក្ដីសង្ឃឹមយ៉ាងកក់ក្ដៅថាសម្ដេចក្រុមព្រះ ទ្រង់ព្រះតម្រិះនូវសំណូមពររបស់ទូលព្រះបង្គំដោយអនុគ្រោះ ។

ទូលបង្គំសូមជូនពរដ៏មហាប្រសើរថ្វាយដល់សម្ដេច សូមទ្រង់ទទួលបាននូវពុទ្ធពរប្រាំប្រការ មានព្រះសុខភាព និងព្រះពលកាយបរិបូណ៌ ដើម្បីជាម្លប់ដ៏ត្រជាក់ដល់ប្រជាពលរដ្ឋខ្មែរយើង ។

សូមទ្រង់មេត្តាទទួលនូវសេចក្ដីគោរពរាប់អានយ៉ាងស្មោះស្ម័គ្រអំពីទូលបង្គំ

ក្រុងមែលប៊ួន ,ថ្ងៃទី២៤ សីហា ១៩៩៦

ធឿន រតនា

អ្នកសំរបសំរួល និងទំនាក់ទំនងសាខា គ.ជ.ខ

គ្រប់រដ្ឋអូស្ត្រាលី

ទីស្នាក់ការ : 14 Carbine Ave , Clayton South
Vic . 3169 . Australia
Tel & Fax : 613 9551 3442

ការិយាល័យប្រតិបត្តិ នៃគណបក្សជាតិខ្មែរ ឆ្នេរសមុទ្រខាងកើតនៃសហរដ្ឋអាមេរិក
EXECUTIVE OFFICE OF KHMER NATION PARTY EAST COAST OF U.S.A
41 Barden Street * Providence, RI 02909 * Tel&Fax (401) 272-7333

Kim, RI
ent
y Tan, NY
e President
. Chea, MA
ce President
Sem, MA
ce President
T
al Secretary
Hun Nhang
sist. Secretary
ath Seng
ssist. Secretary
rn Penh
ssist. Secretary
n Phan
al Treasury
n Duk
sist. Treasury
Nak
ssist. Treasury
n Pich
ssist. Treasury
ISO
Kim
Ros
Ouk
Ly
e Doeur
m Mak
Men
MBERS
Loeu
dent, KNP/RI
r Hou
dent, KNP/MA
ney Nhek
dent, KNP/MA
eang Srun Tek
dent, KNP/CT
n Reach
dent, KNP/NY
om Chhum
dent, KNP/NC

សូមក្រាបថ្វាយបង្គំ សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

សម្ដេចទ្រង់ជ្រាប។

<u>កម្មវត្ថុ:</u> ទទូចស្នើសុំ អត់អោន និង លើកលែងទោសឲ្យ **អតីតអ្នកសារព័ត៌មាន ហែន វិភាគ**

<u>យោង:</u> សេចក្ដីជូនដំណឹងរបស់អគ្គលេខាធិការដ្ឋានគណបក្សជាតិខ្មែរ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩៩៦

សេចក្ដីដូចបានទូលថ្វាយ នៅក្នុងកម្មវត្ថុ និង **យោងខាង**លើនេះ តាងនាមទូលព្រះបង្គំជា ប្រធានការិយាល័យប្រតិបត្តិ សាខាគណបក្ស**ជាតិខ្មែរ** ប្រចាំឆ្នេរសមុទ្រខាងកើតសហរដ្ឋអាមេរិក និង តាងនាមទូលព្រះបង្គំផ្ទាល់ ដែល**ជា**កូនចៅរបស់សម្ដេចឪ ព្រះករុណា ព្រះបាទនរោត្ដម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ **ព្រះរាជាណាចក្រកម្ពុជា** និង ជា **អតីតអ្នកតស៊ូ**នៅក្នុងជួរហ្វ៊ុនស៊ិនប៉ិចមួយរូប ភ្លេចប្រពន្ធកូន នៅឆ្នេរសមុទ្រខាងកើតសហរដ្ឋអាមេរិក តាំងពីឆ្នាំ ១៩៨១ មកដល់ ឆ្នាំ ១៩៩៣ **សូមទទូច អង្វរករ** ស្នើសុំ សូមព្រះអង្គម្ចាស់ នាយករដ្ឋមន្ត្រីទី១ ទ្រង់ព្រះមេត្ដាអត់**អោន និង** លើកលែងទោស ដោយមហាប្រោសប្រណី ដល់លោក ហែន **វិភាគ អតីតចាងហ្វាង**សារព័ត៌មាន "សេរីភាពថ្មី" **និង**ជាបច្ចុប្បន្នសមាជិកគណៈកម្មាធិការនាយកគណ**បក្សជាតិខ្មែរ** ដែលតុលាការកំពូលតុលាការ**តត់អំ**ណាចតុលាការ បានវិនិច្ឆ័យទោស ដោ**យអគតិនិងអ**យុត្តិធម៌ ឲ្យលោក ហែន **វិភាគ** ជាប់គុកT3មួយឆ្នាំ និង ពិន័យជាប្រាក់ចំនួន ប្រាំលានរៀល កាលពីម៉ោង ១០ និង ៣០ នាទីព្រឹក ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩៩៦ **កន្លង**មកនេះ ដោយរាជរដ្ឋាភិបាលចោទថា បានសរសេរផ្សាយព័ត៌មានមិនពិត ក្នុ**ងអត្ថបទ**មួយដែលមានឈ្មោះថា **"ស្រុកចោរ"** ។

បើសិនជា ព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះ **ដែល**គ្រប់គ្រងដោយរាជរដ្ឋាភិបាលរបស់ព្រះ**អង្គ**ម្ចាស់ និង សម្ដេច ហ៊ុន សែន មិនមែ**ន**ជា **"ស្រុកចោរ"**ទេនោះ គឺមិនមានភាពពិតជាក់ស្ដែង ដូចជាអត្ថបទរបស់លោក ហែន **វិភាគ** ដែលបានហ៊ានសរសេរថា ស្រុកខ្មែរ ជា **"ស្រុកចោរ"** នោះ ចំពោះទូលព្រះបង្គំ **ដែលជាអ្នក**លិទ្ធិប្រជាធិបតេយ្យ**និយម និង សច្ចធម៌និយម**មួយរូប ទូលព្រះបង្គំហាក់**ដូចជា**មិនមានយល់ឃើញមានផល

វិបាកណាមួយ ដែលមានឥទ្ធិពលធ្វើឲ្យប៉ះពាល់ ប៉ះទង្គិចទាំងមកលើកិត្តិយសថ្នាក់ដឹកនាំ គឺព្រះអង្គម្ចាស់ និង សម្តេច ហ៊ុន សែន និង ទាំងកិត្តិយសរបស់ជាតិខ្មែរយើង យ៉ាងធ្ងន់ធ្ងរ មហាធ្ងន់ធ្ងរនោះឡើយ។ ដូច្នេះ ក្នុងករណីនេះ ទូលព្រះបង្គំ សូមទទូច អង្វរករ ស្នើសុំ សម្តេចក្រុមព្រះ សូមព្រះអង្គមានព្រះហឫទ័យ អត់អោន និង លើកលែងទោសឲ្យលោកហែម វិភាគ កុលបុត្រជាតិខ្មែររូបនេះ មិនមែនជាសត្រូវពិតរបស់ជាតិខ្មែរ ដែលមានចំណូលចិត្តខាងវិជ្ជាជីវៈសារពត៌មាន ដែលជាវិជ្ជាជីវៈមួយដ៏មានគ្រោះថ្នាក់ លោក ធន់ ប៊ុនលី ជាឧទាហរណ៍ ជាពិសេសនៅកម្ពុជាសព្វថ្ងៃនេះ ដែលនៅមានកំរែលកុម្មុយនីស្តផ្តាច់ការ នៅមានសភាពក្រាស់ឃ្មឹកនៅឡើយ។ សូមមេត្តាអត់អោននិងលើកលែងទោសឲ្យខេមរបុត្ររូបនេះ ជាស្ពាននៅក្នុងអនាគតដ៏ឆាប់បំផុតនេះផង ។
បើសិនជា លោក ហែម វិភាគ បានត្រូវដោះលែងនៅក្នុងថ្ងៃស្អែកនេះ ជាស្ពានមែនទែន ដូចជា លោក ចាន់ រតនា ព្រះអង្គពិតជាមេដឹកនាំមួយអង្គ ដែលសមស្របទៅនឹងសុភាសិតសំស្រ្កឹតមួយឃ្លា ដែលបានពោលថា:" **FORGIVENESS IS THE ORNAMENT OF THE BRAVE** "។

តែបើសិនជា ព្រះអង្គម្ចាស់មានព្រះហឫទ័យយល់ឃើញថា អត្ថបទដែលមានឈ្មោះថា " **ស្រុកចោរ** " របស់លោក ហែម វិភាគនេះ ធ្វើឲ្យប៉ះទង្គិចដល់កិត្តិយសរបស់ព្រះអង្គម្ចាស់ និង កិត្តិយសរបស់ជាតិខ្មែរធ្ងន់ធ្ងរ មហាធ្ងន់ធ្ងរពន់ពេក មិនអាចអត់អោន និង លើកលែងទោសបាននោះ ទូលព្រះបង្គំ ក៏នៅតែទទូចស្នើសុំលក្ខណ្ឌមួយ គឺសូមអង្វរករព្រះអង្គម្ចាស់ ទ្រង់មេត្តាដាក់ព្រះរាជបញ្ជាមួយយ៉ាងតឹងរឹង ហ្មត់ចត់ និងច្បាស់លាស់ ដល់អាជ្ញាធរ ដែលទទួលខុសត្រូវគុកT3 ដែលជាកាកសំណល់កុម្មុយនីស្តឃ្លួនឃ្លានពានដាច់ខាត ឥតមានធ្វើទារុណកម្មបែបណាមួយ ទាំងលើរូបរាងកាយ និង ទាំងលើផ្លូវចិត្តរបស់លោក ហែម វិភាគ អ្នកទោសមនសិការ នេះសោះឡើយ។ ពន្ធនាគារដែលត្រូវដាក់លោក ហែម វិភាគ ជាពន្ធនាគារសំរាប់មនុស្ស ជាគេហដ្ឋានអ្នកកាសែត និង ជាវិមានអ្នកនយោបាយ។ ចំណែកម្ហូបអាហារវិញ ក៏ជាម្ហូបអាហារសំរាប់មនុស្សរបស់មនុស្ស មិនមែនសំរាប់សត្វ ឬ របស់សត្វ និង មានអនាម័យគ្រប់គ្រាន់ ព្រោះថាអ្នកសារពត៌មានជាខ្ញុំកញ្ជះរបស់ប្រជារាស្ត្រ ជាអ្នកឈ្មុសឈ្មុលរុលរកការពិត ទង្វើពិតរបស់រាជរដ្ឋាភិបាលដែលជាអ្នកស៊ីឈ្នួលរាស្ត្រ និង ឯកជន ហើយធ្វើសេចក្តីរាយការណ៍មួយអំពីការពិតនោះ គឺសរសេរផ្សព្វផ្សាយនៅក្នុងខ្ទង់សារពត៌មានរបស់ខ្លួន ជូនសាធារណជន(ប្រជារាស្ត្រ)ទាំងនៅក្នុងប្រទេស និង ទាំងនៅក្រៅប្រទេសដើម្បីជ្រួត

ជ្រាបជាពត៌មាន និង ត្រិះរិះពិចារណា ។ ជាសច្ចធម៌ ការទិះតៀន និងការនិយាយប្រឆាំង អំពីអំពើពុករលួយ អំពើលក់បំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាតិ អំពើផ្តាច់ការ សំឡុតគំរាមកំហែងជិះជាន់សង្កត់សង្កិនបាញ់សម្លាប់ អំពើរំលោភច្បាប់ យកច្បាប់ជាទ្រនាប់ជើង ជាស្បែកជើងជាព្រំ ការមិនគោរពកិច្ចសន្យាជាមួយប្រជារាស្ត្រដែលជាម្ចាស់ប្រទេស ជាម្ចាស់អំណាចសព្វមុខ ឬ ជាម្ចាស់សន្លឹកឆ្នោត។ល។ ដែលជាមុខនាទី និង ជាករណីយកិច្ចរបស់អ្នកសារពត៌មាន ដែលត្រូវតែរំលើកថ្នាក់ដឹកនាំ ដែលត្រូវតែលើកយកមកធ្វើការវែកញែក ទិះតៀន រកហេតុរកផល និង លើកយកមកលាតត្រដាងជូនសាធារណជនជ្រាប ដែលជាការមិនអាចចៀសផុតពីការប៉ះទង្គិច និង ពីការប៉ះពាល់ដល់ថ្នាក់ដឹកនាំបានឡើយ ។ បើថ្នាក់ដឹកនាំ គឺអ្នកមានរដ្ឋអំណាច មានតែហឹង្សាចិត្ត មានតែទោសចិត្ត មានតែចិត្តថ្មខ្មៅ មិនមានខន្តីធម៌ មិនមានមេត្តាធម៌មេត្តាចិត្ត មេដឹកនាំនោះ មិនមែនជាមេដឹកនាំប្រទេស ដើម្បីប្រទេសរបស់ខ្លួន មានសន្តិភាព មានសេចក្តីសុខស្ងប់ក្សេមក្សាន្ត(Internal Tranquility and Peace) នៅក្នុងផ្ទៃប្រទេសរបស់ខ្លួនបានឡើយ។ មេដឹកនាំល្អ ជាមិត្តរបស់ប្រជារាស្ត្រ ជាអ្នកមានសីលធម៌ ព្រហ្មវិហារធម៌ គឺមានមេត្តាចិត្ត និង គតិបណ្ឌិត(WHO HAS POWER, HAS WISDOM)។ ដូច្នេះ ទូលព្រះបង្គំនៅតែទទូចស្នើសុំ ដោយអង្វរករព្រះអង្គម្ចាស់ ដែលទូលព្រះបង្គំមានជំនឿជឿជាក់ថា ព្រះអង្គម្ចាស់ មិនមាន"ព្រះរាជហឫទ័យថ្មខ្មៅ" ដូចមេដឹកនាំកម្ពុជាខ្លះ នឹងអត់អោនលើកលែងទោសពៃរ៍ ដល់លោក ហែន វិភាគ ដែលមិនមែនមិនមានទោសកំហុសនោះទេ ដែលជាអ្នកកាសែត មានតែឧត្តមគតិជាតិ មានតែក្រដាស និង មានតែស្លាបប៉ាក្កា មិនទាមទារការងាររាជការ សរសេរដើម្បីក្រពះរបស់ខ្លួនផង និង ដើម្បីប្រទេសជាតិមាតុមាតុភូមិរបស់ខ្លួនរស់ផង មានសន្តិភាព សេរីភាព លិទ្ធិប្រជាធិបតេយ្យ ដែលជាមូលហេតុនៃអភិវឌ្ឍនភាព និង សុភមង្គល រុងរឿងឡើងវិញផង ។

ជាទីបញ្ចប់នេះ ទូលព្រះបង្គំមានជំនឿ និង សេចក្តីសង្ឃឹមមុតមាំថា ព្រះអង្គម្ចាស់នឹងអត់អោនលើកលែងទោសឲ្យលោក ហែន វិភាគ ដូចដែលព្រះអង្គម្ចាស់បានធ្លាប់អត់អោនលើកលែងទោសឲ្យលោក ចាន់ រតនា ដែលជាអ្នកសារពត៌មានហ៊ានទិះតៀនព្រះអង្គម្ចាស់ ជាស្ថាពរ និង ជាពិតប្រាកដ ដែលជាពន្លឺល្អមួយទៀតខ្លះបញ្ជាក់ឲ្យឃើញថា ព្រះអង្គម្ចាស់ ជាមេដឹកនាំប្រទេសជាតិមាតុភូមិខ្មែរ ដែលមានទាំងអំណាចរដ្ឋផង និង ទាំងព្រហ្មវិហារធម៌ផង គឺមានសីលធម៌ មានមេត្តាធម៌ និង មានគតិបណ្ឌិតផង។

សូមព្រះអង្គម្ចាស់ នាយករដ្ឋមន្ត្រីទី១ មេត្តាទទួលនូវសេចក្តីគោរពដ៏ស្មោះ អំពីទូល

ព្រះបង្គំ ។

ធ្វើនៅទីក្រុងប្រវិដិន្ស រដ្ឋរ៉ូដអៃឡិន្ត ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ១៩៩៦

គឹម សុរិយា ប្រធានការិយាល័យប្រតិបត្តិ សាខាគណបក្សជាតិខ្មែរ
ប្រចាំឆ្នេរសមុទ្រខាងកើត សហរដ្ឋអាមេរិក

<u>**ចំឡងថ្វាយនិងជូន:**</u>

-ព្រះករុណាសម្តេចឪ ព្រះបាទនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា
-លោក សម រង្ស៊ី អតីតអ្នកដំណាងរាស្ត្រ និង បច្ចុប្បន្នប្រធានគណបក្សជាតិខ្មែរ
-លោក ឡេង គឹម អាន ប្រធាន សាខាគណបក្សជាតិខ្មែរ ប្រចាំសហរដ្ឋអាមេរិក
-លោក គុយ ម៉ារុង ប្រធាន សាខាគណបក្សជាតិខ្មែរ ប្រចាំប្រទេសកាណាដា
-លោក ហាក់ ចាន់សុខុម ប្រធានសាខាគ.ជ.ខ.ប្រចាំឆ្នេរសមុទ្រខាងលិចស.រ.អា.
-លោក ប៉ាត សុយត្រី ប្រធានសាខាគ.ជ.ខ.ប្រចាំភូមិភាគកណ្តាលស.រ.អា.
-លោក តាន់ហុកឃី(ញូវយក)អនុប្រធានសាខាគ.ជ.ខ.ប្រចាំឆ្នេរសមុទ្រខាងកើតស.រ.អា
-លោក ជា គឹមលី(ម៉ាសាឈូសិត)អនុប្រធានសាខាគ.ជ.ខ.ប្រចាំឆ្នេរសមុទ្រខាងកើត
-លោក សែម វ៉ាន់ឌី(ម៉ាសាឈូសិត)អនុប្រធានសាខាគ.ជ.ខ.ប្រចាំឆ្នេរសមុទ្រខាងកើត
-លោក លី ខា ប្រធានសាខារងគ.ជ.ខ. ប្រចាំរដ្ឋរ៉ូដអៃឡិន្ត
-លោកហ៊ូ សឿរ ប្រធានសាខារងគ.ជ.ខ.ប្រចាំដំបន់ខាងកើត/ខាងលិចម៉ាសាឈូសិត
-លោក ញឹក រស្មី ប្រធានសាខារងគ.ជ.ខ.ប្រចាំក្រុងឡូវែល រដ្ឋម៉ាសាឈូសិត
-លោក សេង លី ប្រធានសាខារងគ.ជ.ខ. ប្រចាំដំបន់អាំហឺស រដ្ឋម៉ាសាឈូសិត
-លោក រាជ សុគុន ប្រធានសាខារងគ.ជ.ខ.ប្រចាំទីក្រុងញូវយក
-លោក តិច ឈាងស្រុន ប្រធានសាខាគ.ជ.ខ.ប្រចាំរដ្ឋកូណិចទិខិត
-លោក ឈុំ សុខុម ប្រធានសាខារងគ.ជ.ខ.ប្រចាំរដ្ឋការ៉ូលីណា
-លោក នូ ឃ្លាំង ប្រធានសាខារងគ.ជ.ខ.ប្រចាំរដ្ឋមីស្សូរី
-សារពត៌មានជាតិខ្មែរ នៅក្នុងប្រទេស និង នៅក្រៅប្រទេស ហើយនិង ឯកសារ